# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ថ្ងៃពុធ ៩កើត ខែភទ្របទ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែ កញ្ញា ឆ្នាំ២០២១

**និយ័តករគណនេយ្យនិងសវនកម្ម**
លេខ..០១៦.......... ន.គ.ស សណន

**សេចក្តីណែនាំ**

**ស្តីពី**

**ការបញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២០ដែលរងសវនកម្មឯករាជ្យរួច តាមប្រព័ន្ធអនឡាញសម្រាប់សហគ្រាសដែលទទួលបានការអនុញ្ញាតពន្យារពេលពី ន.គ.ស និងសហគ្រាសដែលបិទបញ្ជីគណនេយ្យខុសពីថ្ងៃទី៣១ ខែធ្នូ**

**និយ័តករគណនេយ្យនិងសវនកម្ម** មានកិត្តិយសសូមជម្រាបជូនដល់ម្ចាស់សហគ្រាសដែលទទួលបានលិខិតអនុញ្ញាតពន្យារពេល និងសហគ្រាសដែលបិទបញ្ជីគណនេយ្យខុសថ្ងៃទី៣១ ខែធ្នូ ទាំងអស់មេត្តាជ្រាបថា៖ ដើម្បីធានាប្រសិទ្ធភាពនៃការបញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលរងសវនកម្មឯករាជ្យរួច មកនិយ័តករគណនេយ្យ និងសវនកម្ម តាមពេលវេលាកំណត់ **និយ័តករគណនេយ្យនិងសវនកម្ម** សូមធ្វើការណែនាំដូចខាងក្រោម៖

១. សហគ្រាស ត្រូវទាក់ទងមកនិយ័តករគណនេយ្យនិងសវនកម្ម ជាមុន ដើម្បីទទួលបានសិទ្ធិចូលប្រើប្រាស់ប្រព័ន្ធ E-Filling ស្របតាមការសេចក្តីណែនាំលេខ ០០៩ ន.គ.ស.សណន ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២១ស្តីពីបែបបទនិងនីតិវិធីនៃការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលរងសវនកម្មឯករាជ្យរួចសម្រាប់សហគ្រាស តាមប្រព័ន្ធអនឡាញ មកនិយ័តករគណនេយ្យនិងសវនកម្ម។

២. សហគ្រាសដែលទទួលបានការពន្យារពេលបន្ថែមរួចហើយ ត្រូវអនុវត្តតាមពេលវេលាដែលបានកំណត់ក្នុងលិខិតអនុញ្ញាត។

៣. សហគ្រាសដែលបិទបញ្ជីគណនេយ្យប្រចាំឆ្នាំខុសពីថ្ងៃទី៣១ ខែធ្នូ ត្រូវអនុវត្តតាមគោលការណ៍រយៈពេល ៦ ខែ បូក ១៥ ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ។

សហគ្រាស នឹងទទួលរងពិន័យអន្តរការណ៍ក្នុងករណីនិយ័តករគណនេយ្យនិងសវនកម្ម បានរកឃើញថាសហគ្រាសមិនបានគោរពតាមសេចក្តីណែនាំនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមម្ចាស់សហគ្រាស មេត្តាជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តខ្លឹមសារនៃសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់។

**និយ័តករគណនេយ្យនិងសវនកម្ម**


**ទំនាក់ទំនង៖**

**ក. ផ្នែកស្នើសុំប្រើប្រាស់ប្រព័ន្ធ E-Filling**

១. លោក ជីវ ហ៊ : ០១០ ៣០៤ ៤៧០

២. លោក ជ វិត្ថនា : ០៨៧ ៨៤៣ ៤៧០

៣. លោកស្រី សេង ស៊ីណា : ០៩៣ ៩១៩ ១៩២

៤. លោក វ៉ាត ភិរុណ : ០១០ ៧៣៦ ៨៣៥